ព្រះរាជាណាចក្រ កម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣៨៨
ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥
<u>សាលដីកា</u>
លេខ:២៤៨
ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន
២-លោក **រៀល មួន** ជាចៅក្រម
៣-លោក **ស៊ិន ឌឹម** ជាចៅក្រម
៤-លោក **ម៉ុង មុន្នីចរិយា** ជាចៅក្រម
៥-លោក **យូរ ឧត្តរា** ជាចៅក្រម
<u>ក្រឡាបញ្ជី</u>
-លោកស្រី **យុន សគន្ធា**
<u>តំណាងមហាអយ្យការ</u>
-លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៩២(ឈ) ចុះថ្ងៃទី០៧-៦-២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៨៧ ចុះថ្ងៃទី២០-១២-២០០៤ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះលឹម សុខុម (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីលំនៅភូមិធំថ្មី ឃុំ-ស្រុកដងទង់ ខេត្តកំពត ។ ផ្ទេរសិទ្ធិឱ្យ ឈឹម ណាន

<u>មេធាវី:</u> លោក ចាន់ វណ្ណៈ

និងចុងចម្លើយឈ្មោះ ញ៉ែត ឌី (ជាដើមបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ ៤៩ឆ្នាំ ជាតិខ្មែរមុខរបរនគរបាល ទីលំនៅភូមិធំថ្មី ឃុំ ស្រុកដងទង់ ខេត្តកំពត ។

**<u>កម្មវត្ថុបណ្តឹង</u>**:ប្តឹងសុំបណ្តេញចេញពីផ្ទះ និងទាមទារថ្លៃឈ្នួលផ្ទះ.

តាមបណ្តឹងសាទុក្ខលេខ ២៣២ ថ្ងៃទី១៥-០៦-២០០៥ របស់ឈ្មោះញ៉ែត ឌី ប្តឹងមិនសុខចិត្តនិងសាលដីកាលេខ៩២(ឈ)ចុះថ្ងៃទី ០៧-០៦-២០០៥ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៨៨ ចុះថ្ងៃទី ២៩-៨-២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ លឹម សុខុម ចុះថ្ងៃទី១១-១២-២០០២ បញ្ជាក់ថា: ខ្លួនប្តឹងសុំឱ្យចុងចម្លើយឈ្មោះ ញ៉ែត ឌី គោរពតាមកិច្ចសន្យាលក់-ទិញផ្ទះ និង កិច្ចសន្យាជួលផ្ទះ ដោយ

សន្យាឱ្យថ្លៃឈ្នួលផ្ទះក្នុងមួយខែចំនួន៥០ដុល្លា ប៉ុន្តែរហូតមកដល់ពេលនេះ គឺមានរយៈពេល ២ឆ្នាំហើយ ដែលចុងចម្លើយ . មិនបានបង់ថ្លៃឈ្នួលផ្ទះ ។ ដូច្នេះខ្លួនសុំឱ្យចុងចម្លើយឈ្មោះ ញ៉ែត ឌី សងថ្លៃឈ្នួលផ្ទះ មកខ្លួនវិញ ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ ១១/២២-១១-២០០២ របស់តុលាការខេត្តកំពត,

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ ៥១/០៦-១២-២០០២ របស់តុលាការខេត្តកំពត.

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៩(ខ)/២៤-៣-២០០៣ របស់សាលាឧទ្ធរណ៍.

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៨៥/២២-៤-២០០៤ របស់តុលាការកំពូល

បានឃើញសាលក្រមរដ្ឋប្បវេណី១២៥ ចុះថ្ងៃទី ២៧-៨-២០០៤ របស់តុលាការខេត្តកំពត ដែលសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី១១-១១-២០០២ របស់ឈ្មោះលឹម សុខុម ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះញ៉ែត ឌី និងប្រពន្ធឈ្មោះខៃ សារុន ចុះចេញពីផ្ទះ និង ប្រគល់ផ្ទះដែលមានចុះនៅក្នុងកិច្ចសន្យាលក់ ចុះថ្ងៃទី០៥-៦-០២ ទៅឱ្យឈ្មោះលឹម សុខុម និងប្រពន្ធឈ្មោះឈឹម ណាន ជាកម្មសិទ្ធិចាប់ពីថ្ងៃសាលក្រមមានអានុភាពអនុវត្ត ។

៣-បង្គាប់ឈ្មោះញ៉ែត ឌី និងប្រពន្ធឈ្មោះខៃ សារុន បង់ថ្លៃឈ្នួលផ្ទះ៥០ដុល្លា ក្នុងមួយខែដូចមានចែងក្នុងកិច្ចសន្យាជួលផ្ទះចុះថ្ងៃទី០៥-៦-២០០២ ចាប់ពីខែកញ្ញា ឆ្នាំ២០០៦ រហូតដល់ឈ្មោះញ៉ែត ឌី និងប្រពន្ធបានចុះចេញពីផ្ទះជួលនោះ រួចរាល់ ។

៤-បង្គាប់ឱ្យឈ្មោះ ញ៉ែត ឌី និងប្រពន្ធសងជម្ងឺចិត្តថ្លៃខាតបង់ពេលវេលា សោហ៊ុយផ្សេងៗចំនួន ២០០០ដុល្លារ សំណូមពរសុំលើសពីនេះបដិសេធចោល ។ ករណីរឹងរូសពុំព្រមសងត្រូវដាក់គុក បង្ខំរូប-កាយនៅពេលសាលក្រមនេះចូលជាស្ថាពរ ។

៥-បង្គាប់ឱ្យឈ្មោះញ៉ែត ឌី បង់ប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០ ៛ ដើម្បីជាត់ចែងតាមច្បាប់ ។

កាលបើហួសឧទ្ធរណ៍បង្គាប់ឱ្យឈ្មោះ ញ៉ែត ឌី បង់ពន្ធសមាមាត្រ ១% លើតម្លៃផ្ទះ ៥.០០០ដុល្លា និង មួយភាគរយលើជម្ងឺចិត្ត បូកនឹងប្រាក់ឈ្នួលផ្ទះ ។

សាលក្រមនេះជំនុំជំរះជាសាធារណៈ និងប្រកាសជាសាធាណៈចំពោះមុខគូក្ដី សម្រេចបើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានឈ្មោះញ៉ែត ឌី ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ៥៥/១៨-១០-២០០៤ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីកាលខ ៩២(ឈ) ០៧-០៦-២០០៥ របស់សាលាឧទ្ធរណ៍ដែលសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨-១០-២០០៤ របស់ឈ្មោះញ៉ែត ឌី ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១២៥ ចុះថ្ងៃទី ២៧-៨-២០០៤ របស់តុលាការខេត្តកំពត ចេញជាអសារបង់ ។

៣-ទុកជាមោឃៈកិច្ចសន្យាលក់ផ្ទះ កិច្ចសន្យាទិញផ្ទះវិញ និងកិច្ចសន្យាជួលផ្ទះចូនថ្ងៃទី០៥-៦-២០០២ រវាងដើមចោទ និងចុងចម្លើយទាំងមូល ។

៤-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ចំនួន ៥.០០០ដុល្លា (ប្រាំពាន់ដុល្លាអាមេរិក) ការប្រាក់៥%ក្នុងមួយឆ្នាំលើប្រាក់ដើម ចាប់គិតពីថ្ងៃទី ២០-៨-២០០២ រហូតដល់ថ្ងៃសងគ្រប់ចំនួន និង ជម្ងឺចិត្តចំនួន ១.៥០០ ដុល្លា (មួយពាន់ប្រាំរយដុល្លាអាមេរិក) ទៅឱ្យដើមចោទនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

ក្នុងករណីចុងចម្លើយគ្មានប្រាក់សង អនុញ្ញាតឱ្យរឹបអូសទ្រព្យសម្បត្តិចុងចម្លើយលក់ឡាយឡុងដើម្បីយកប្រាក់សងដើមចោទ ។

៥-តម្កល់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ ដែលដើមចោទបានបង់ទុករួចហើយគឺៈ

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ចំនួន ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ចំនួន ៥.០០០៛ និង លើអាជ្ញាធរតុលាការចំនួន ៥.០០០៛ ។

៦-បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ ១% លើទឹកប្រាក់ដែលសម្រេចក្នុងចំណុចទី នៃសាលដីកានេះ ។

៧-សាលដីកានេះជំនុំជំរះនៅថ្ងៃទី ៣០-៥-២០០៥ ចំពោះមុខគូក្តី និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៧-០៦-២០០៥ ចំពោះមុខគូក្តី ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៣២ ចុះថ្ងៃទី ១៥-០៦-២០០៥ របស់ឈ្មោះ ញ៉ែត ឌី ស្ថិតក្នុងកំណត់ច្បាប់ ។

បានឃើញសារណារបស់ញ៉ែត ឌី ចូរថ្ងៃទី០៨-១០-២០០៥.

បានឃើញសារណាតបរបស់អ្នកស្រីឈឹម ណាន ចុះថ្ងៃទី១៩-១០-២០០៥

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សាលដីការដ្ឋប្បវេណីលេខ៩២(ឈ) ចុះថ្ងៃទី ០៧-០៦-២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ ។

បានស្តាប់ចម្លើយរបស់លោក ញ៉ែត ឌី នាពេលសវនាការថាៈ ផ្ទះនេះខ្លួនមិនបានលក់ដូរទេកិច្ចសន្យា នេះគ្រាន់តែធ្វើដើម្បីជានាប្រាក់ខ្ចីប៉ុណ្ណោះ ។ បើលក់មិនមែនខ្លួនទទួលលុយលើកទី១ ៣.០០០ដុល្លា លើកទី២ ១.០០០ដុល្លា និងលើកទី៣ ១.០០០ដុល្លា នោះទេ តើខ្លួនអាចយកទៅទិញផ្ទះអីបាន ។ ខ្លួនបានឱ្យការប្រាក់៤ ខែ គឺ១ខែ ៥០ដុល្លា ។

បានស្តាប់ចម្លើយរបស់អ្នកស្រីឈឹម ណាន នាពេលសវនាការថាៈ ពីដើមឡើយមានកិច្ចសន្យាលក់ទិញផ្ទះមែន តែគាត់ប្រកែកថាជារឿងចងការ ឯខ្លួនក៏មិនចង់វែងឆ្ងាយ សុខចិត្តទទួលយកតាមនេះចុះ ។

លោកចាន់ វណ្ណៈ មេធាវីការពារឱ្យដើមចោទបានសន្និដ្ឋានថាៈ ញ៉ែត ឌី បានទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់ប្រាក់កូនក្តីលោកចំនួន ៥.០០០ដុល្លាមែន តែដល់សាលាឧទ្ធរណ៍សម្រេចឱ្យសងគាត់បែរជាប្តឹងសាទុក្ខទៅវិញ ។

សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ
-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣២ ចុះថ្ងៃទី១៥-៦-២០០៥ របស់លោកញ៉ែត ឌី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៩ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចទទួលស្គាល់ប្រាក់ចំនួន ៥.០០០ដុល្លា ជាប្រាក់បំណុល ចងការនោះជាការត្រឹមត្រូវហើយ ប៉ុន្តែការដែលសាលាឧទ្ធរណ៍សម្រេចឲ្យចុងចម្លើយសងបំណុលទៅដើមចោទចំនួន ៥.០០០ដុល្លា និងជម្ងឺចិត្ត ១.៥០០ដុល្លា បន្ថែមទៀតនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថានាសវនាការនេះដើមចោទ ទទួលស្គាល់ថាច្បាប់បានទទួលឈ្នួលផ្ទះ(ការប្រាក់) ចំនួន៣ខែស្មើនឹង១៥០ដុល្លា ដែលគប្បីសាលាឧទ្ធរណ៍សម្រេចតាមការ កំណត់នៃមាត្រា ៥៩,៦០ នៃក្រិត្យ-ច្បាប់លេខ៣៨ក្រ-ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ម្យ៉ាងទៀតការសម្រេចអំពីជម្ងឺចិត្តក៏ពុំទាន់មានមូលហេតុច្បាស់លាស់ដែរ ពីព្រោះដើមចោទពុំទទួលព្យសនៈកម្មអ្វីធ្ងន់ធ្ងរទេ ហើយក៏ធ្លាប់បានបង្កការលំបាកច្រើនដល់ចុងចម្លើយដែរ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៩២(ឈ) ចុះថ្ងៃទី ០៧-០៦-២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ២៣២ ចុះថ្ងៃទី១៥-៦-២០០៥ របស់លោកញ៉ែត ឌី ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៩២(ឈ) ចុះថ្ងៃទី ០៧-៦-២០០៥ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨៨/១៩-៨-២០០៥ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលដើមចោទ បានបង់គឺៈ

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ។

-ចំណាយលើកាប្រគល់ដីកោះចំនួន១៥.០០០រៀល សរុប១៩០០០៛ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦ ។